# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ.................................ស.ខ.ក.ក.

## សុន្ទរកថា

ឯកឧត្តម ថាច់ សេដ្ឋា នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម
សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងជាអតីតសមាជិកព្រឹទ្ធសភា
ក្នុងពិធីកាន់ទុក្ខជាតិខ្មែរ គំរប់ខួប៦១ឆ្នាំ ថ្ងៃអាណានិគមបារាំងកាត់ទឹកដីខ្មែរឱ្យវៀតណាម
*នៅវត្តសាមគ្គី ញ៉ូវ៉ រាជធានីភ្នំពេញ "០៤-៦-១៩៤៩_០៤-៦-២០១០"*

_សូមនមស្សការចំពោះប្រជុំបីនៃព្រះត្រៃរតន៍ !
_សូមគោរព និងក្រាបថ្វាយបង្គំ ព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិដ៏ខ្ពង់ខ្ពស់ !
_សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ !
_សូមថ្វាយបង្គំ សម្តេចស៊ីសុវត្ថិ ពង្សនារី មុនីពង្ស ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាព្រះអធិបតីដ៏ខ្ពង់ខ្ពស់ !
_សូមគោរព សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសជាតិ អន្តរជាតិទាំងអស់ ជាទីស្នេហា !

ជាបឋម តាងនាមព្រះសង្ឃ ប្រជានុរាស្ត្រខ្មែរកម្ពុជាក្រោម និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ សូមព្រះបរមរាជានុញ្ញាត ថ្លែងនូវអំណរព្រះមហាករុណាទិគុណយ៉ាងជ្រាលជ្រៅបំផុត ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រោសព្រះរាជទាន *សម្តេច* ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ធ្វើជាព្រះអធិបតីក្នុងពិធីបុណ្យជាប្រវត្តិសាស្ត្រនាពេលនេះ ។ ព្រះរាជហឫទ័យប្រកបដោយព្រះមេត្តាធម៌ដ៏ឧត្តុង្គឧត្តមនេះ មិនមែនជាលើកទី១ទេ គឺចាប់តាំងពីឆ្នាំ២០០០ នៃសហស្សវត្សរ៍ថ្មីក្នុងរជ្ជកាលព្រះកុណាព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះនរោត្តម សីហនុ រហូតមកបច្ចុប្បន្ន ព្រះអង្គតែងតែប្រោសព្រះរាជទានព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ធ្វើជាព្រះអធិបតីក្នុងពិធីបុណ្យជាប្រវត្តិសាស្ត្រនេះ មិនដែលខកខានម្តងណាឡើយ ។ នេះជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីការយកព្រះទ័យទុកដាក់ និងអាណិតអាសូររបស់ព្រះកុណាព្រះមហាក្សត្រខ្មែរនៃយើង ចំពោះព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមដ៏ពិតប្រាកដ ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះដែរ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតថ្លែងនូវកតញ្ញុតាធម៌ និងអំណរព្រះមហាករុណាទិគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ថ្វាយព្រះករុណាព្រះមហាវីរក្សត្រ សម្តេចឪសម្តេចម៉ែ សម្តេចតា សម្តេចយាយ សម្តេចតាទួត សម្តេចយាយទួត ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ដែលតែងតែលើកទឹកចិត្ត និង

**ទីស្នាក់ការបណ្ដោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ**
**ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៨៣៣ ០០៣**
E-mail: senthach2000@yahoo.com; Website: http//khmerkromngo.org

ប្រទាននូវការឧបត្ថម្ភគាំទ្រដល់គ្រប់សកម្មភាពតស៊ូស្របច្បាប់របស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមជានិច្ច ជាពិសេស បានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យផ្ទាល់ចំនួន២០០០ដុល្លារសហរដ្ឋអាមេរិក ដើម្បីរៀបចំពិធីបុណ្យជារៀងរាល់ឆ្នាំ ។ នេះជាព្រះមហាករុណាទិគុណដ៏មហាធំធេងដែលទូលព្រះបង្គំ ជាកូន ជាចៅ ចៅទួតរបស់ព្រះអង្គ ចងចាំជានិច្ចមិនអាចបំភ្លេចបានឡើយ ។

ជារៀងរាល់ឆ្នាំ ចាប់ពីសហស្សវត្សរ៍ថ្មីឆ្នាំ២០០០រហូតមក នៅថ្ងៃនេះ (០៤មិថុនា) យើងខ្ញុំជាប្រជាជាតិខ្មែរ ដែលបានកើតនៅលើទឹកដីកម្ពុជាក្រោម នៅជុំវិញពិភពលោក តែងតែប្រារព្ធពិធីកាន់ទុក្ខ និងនិមន្តព្រះសង្ឃចំនួន១៩៤៩អង្គ រាប់បាត្រជានិច្ច ដើម្បីសម្តែងនូវការសោកស្តាយអាល័យស្រណោះ ចំពោះមាតុភូមិខ្មែរដ៏បវរនៃយើង ដែលបានបាត់បង់ទាំងអយុត្តិធម៌ ដោយសារស្នាដៃដ៏ខ្មៅកខ្វក់របស់អាណានិគមបារាំង ។ ពិធីនេះក៏ជាការសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិទាំងអស់ ដែលបានបូជាព្រះកាយ បូជាកាយ ក្នុងបុព្វហេតុជាតិ មាតុភូមិ ព្រះពុទ្ធសាសនា សិល្បៈ វប្បធម៌ អក្សរសាស្ត្រ និងប្រពៃណីជាតិខ្មែរ ជាពិសេស មាតុភូមិខ្មែរកម្ពុជាក្រោម ហើយក៏ជាការបង្ហាញឲ្យសហគមន៍ជាតិ អន្តរជាតិ បានដឹង បានឮ បានឃើញយ៉ាងច្បាស់ នូវទុក្ខសោកវេទនាយ៉ាងឈឺចាប់បំផុត នៃជនរួមឈាមខ្មែរ ដែលកំពុងរស់នៅក្រោមនឹមដែកអម្រែកថ្ម របស់អាណានិគមវៀតណាមផងដែរ ។

ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០នេះ ជាខួបគំរប់៦១ឆ្នាំ នៃថ្ងៃអាណានិគមបារាំងបានប្រកាសជាផ្លូវការ ឲ្យប្រើប្រាស់ច្បាប់ដ៏ទុយ៌សម្ពយលេខ៤៩-៧៣៣ ដែលជាច្បាប់កាត់យកទឹកដីខ្មែរប៉ែកខាងក្រោម (កម្ពុជាក្រោម) មានទំហំផ្ទៃដី ៦៨.៩៦៥ គីឡូម៉ែត្រក្រឡា បច្ចុប្បន្នមានប្រជារាស្ត្រខ្មែររស់នៅជាង១៣លាននាក់ ផ្ទេរឲ្យអាណាព្យាបាលអាណានិគមវៀតណាមត្រួតត្រាបន្តរហូតដល់សព្វថ្ងៃ ដោយមិនបានសួរមតិប្រជារាស្ត្រខ្មែរជាម្ចាស់ ឬថ្នាក់ដឹកនាំនៃព្រះរាជាណាចក្រខ្មែរឡើយ ។ ច្បាប់នេះមានខ្លឹមសារទាំងស្រុងដូចខាងក្រោម :

Loi N°49-733 du 4 Juin 1949 modifieant le statut de la Cochinchine dans l'Union française. Aprés avis de l'Assemblée nationale de l'Union française, L'Assemblée nationale et le Conseil de la République ont délibéré, L'Assemblée nationale a adopté, Le Président de la République promulgue le loi don't la teneur suit:

Art. 1er – Dans le cadre fixé á L'article 60 le la Constitution de la Républicque francaise et aprés l'avis émis, dans sa séance du 23 april 1949, par l'Assemblée territoriale de Cochinchine, le statut de la Cochinchine est modifié dans les conditions prévues á l'article ci-aprés.

Atr. 2.- Le territoire de la Cochinchine est rattaché á l'Etat associé du Viet-Nam suivant les termes de la declaration commune du 5 juin 1948 et de la declaration du Gouvernement française du 19 août 1948. La Cochinchine cesse en conséquesnce d'avoir le statut de teritoire d'outre-mer.

Art. 3- En cas de changement du statut du Viet-Nam, le statut de la Cochinchine fera l'objet d'une nouvelle deliberation des assemblées prévues á l'article 75 de la Constitution (Titre VIII: De l'Union française).

La présente loi sera execute comme loi de l'Etat. Fait á Toulon, le 4 Juin 1949.

| | | |
|---|---|---|
| **VINCENT AURIOL** | **HENRI QUEUILLE.** | **PAUL COSTE-FLORET.** |
| 1er le Président de la République: | Le president du conseil des ministres, | Le Ministére de la France d'outre-mer, |

ប្រែជាភាសាខ្មែរក្រៅផ្លូវការថា ច្បាប់លេខ៤៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩

យោងមតិពីរដ្ឋសភានៃសហភាពបារាំង រដ្ឋសភា និងក្រុមប្រឹក្សានៃសាធារណរដ្ឋបារាំងបានសម្រេច រដ្ឋសភានៃសាធារណរដ្ឋបារាំងបានអនុម័ត

*ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ប្រកាសច្បាប់ដូចតទៅនេះ :*

-មាត្រា១: ក្នុងក្របខណ្ឌមាត្រា៦០ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំង និងតាមមតិរបស់សភាកូសាំងស៊ីន នាសម័យប្រជុំថ្ងៃទី២៣ មេសា ១៩៤៩ លក្ខន្តិកៈទឹកដីកូសាំងស៊ីនត្រូវកែប្រែតាមមាត្រាដូចមានចែងខាងក្រោម ។

-មាត្រា២: ទឹកដីកូសាំងស៊ីនត្រូវបានភ្ជាប់ទៅជារដ្ឋចំណុះវៀតណាម យោងតាមសេចក្តីប្រកាសរួមកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៤៨ និងសេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំង កាលពីថ្ងៃទី១៩ សីហា ១៩៤៨ ។ ទឹកដីកូសាំងស៊ីនឈប់ស្ថិតនៅក្នុងលក្ខន្តិកៈជាទឹកដីឯនាយសមុទ្ររបស់បារាំងទៀតហើយ ។

-មាត្រា៣: ក្នុងករណីដែលលក្ខន្តិកៈប្រទេសវៀតណាមត្រូវកែប្រែ លក្ខន្តិកៈកូសាំងស៊ីននឹងត្រូវទុកជាកម្មវត្ថុនៃការសម្រេចរបស់សភាខាងលើ ដូចមានចែងក្នុងមាត្រា៧៥ នៃរដ្ឋធម្មនុញ្ញជំពូកទី VIII : សហភាពបារាំង ។ ច្បាប់នេះនឹងត្រូវអនុវត្តដូចជាច្បាប់រដ្ឋ ។

ធ្វើនៅទូឡុង ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩

ហត្ថលេខា

| | | |
|---|---|---|
| *វ៉ាំងសង់ អូរីយ៉ូល* | *ហង់រី ក្វើយ* | *ប៉ូល កូស្ត-ផ្លូរេត* |
| ប្រធានាធិបតី | នាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ |

*បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
*គណៈអធិបតីជាទីគោរព*
*បងប្អូនរួមជាតិជាទីស្នេហា*

ផ្តើមចេញពីច្បាប់ ពុះចែកបំបែកទឹកដីខ្មែរបង្វែរឲ្យអាជ្ញាធរអាណានិគមវៀតណាម របស់អាណានិគមបារាំង សោកនាដកម្មដ៏សែនឈឺចាប់រាប់មិនអស់បានកើតមានឡើងចំពោះប្រជារាស្ត្រ និងព្រះសង្ឃខ្មែរដែលជាម្ចាស់ទឹកដីគ្មានពេលស្រាកស្រាន្ត ។ ទឹកភ្នែកក្លាយជាឈាម ឪពុកព្រាត់កូន ជីដូនព្រាត់ចៅ ប្តីព្រាត់ប្រពន្ធ គ្រូព្រាត់សិស្ស ។ ព្រះឧបជ្ឈាយ៍ ព្រះចៅអធិការ ព្រះពហុស្សូត្រ គ្រូអាចារ្យ ឧបាសក ឧបាសិកា ទាយក ទាយិកា ដែលជាបញ្ញវ័ន្តខ្មែរត្រូវអាជ្ញាធរអាណានិគមវៀតណាមចាប់ដាក់ខ្នោះបញ្ចូលគុក និងធ្វើទារុណកម្មយ៉ាងសែនវេទនាជាទីបំផុត ។ ទំនៀមទម្លាប់ សិល្បៈ វប្បធម៌ អក្សរសាស្ត្រ វត្តអារាមព្រះពុទ្ធសាសនា និងប្រពៃណីខ្មែរ ត្រូវរងការបំផ្លិចបំផ្លាញយ៉ាងព្រៃផ្សៃ ជាក់ស្តែងដូចនៅខេត្តកំពង់ឫស្សី ដែលយួនបានប្តូរឈ្មោះទៅជាខេត្តបេនត្រែ វត្តព្រះពុទ្ធសាសនាខ្មែរចំនួន២៥វត្ត ត្រូវបានអាជ្ញាធរអាណានិគមយួនកម្ទេចចោលទាំងស្រុង ហើយប្រជារាស្ត្រខ្មែរនៅទីនោះ ត្រូវបានហាមមិនឲ្យនិយាយភាសារខ្មែរជាដាច់ខាត់ ។ បច្ចុប្បន្ន ប្រជារាស្ត្រខ្មែរនៅខេត្តនេះពុំមាននរណាចេះនិយាយភាសាខ្មែរឡើយ គ្រាន់តែនៅមានអ្នកខ្លះនៅចាំបានថាខ្លួនមានឈាមជ័រជាខ្មែរ ដោយសារដូនតារបស់ខ្លួនបានដំណាលប្រាប់តៗគ្នាមកតែប៉ុណ្ណោះ ។ រីឯវត្តអារាមនៅទីកន្លែងផ្សេងៗទៀត ក៏ត្រូវអាជ្ញាធរអាណានិគមវៀតណាម កម្ទេចចោលស្ទើរ ទាំងស្រុងដែរ ។

នៅឆ្នាំ១៨១៥ ដល់ឆ្នាំ១៨១៩ យួនបានប្រើយុទ្ធសាស្ត្រសម្លាប់ប្រជារាស្ត្រខ្មែរនៅក្នុងការដ្ឋានព្រែកជីកវិញតែអស់ជាង៤០០០នាក់ ។ នៅឆ្នាំ១៩៤៥ យួនបានដុតសម្លាប់ប្រជារាស្ត្រខ្មែរទាំងរស់នៅខេត្តពលលាវ ជាង៧០០០នាក់ ។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ អាជ្ញាធរអាណានិគមយួនបានប្រើប្រាស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អមដោយរថក្រោះ រថពាសដែក បានធ្វើការបាញ់ប្រហារយ៉ាងឃោរឃៅមកលើប្រជារាស្ត្រខ្មែរ ដែលធ្វើការតវ៉ាទាមទារសិទ្ធិសេរីភាព បណ្តាលឲ្យស្លាប់ចំនួន៦៥នាក់ របួសជាង៥០០នាក់ ចាប់ខ្លួនដាក់ពន្ធនាគារ និងធ្វើទារុណកម្មជាង៨០០០នាក់ កាត់ទោសប្រហារជីវិតចំនួន៣នាក់ គឺ លោក ថាច់ គឹន លោក ថាច់ ឌៀក និងលោក គឹម វី ។ ជាប់គុកអស់មួយជីវិតចំនួន៦នាក់គឺ ១-លោក សឺន ញ៉ ២-លោក កៀង សើង ។ ៣-លោក កៀង ហាន ។ ៤-លោក ថាច់ ដេន ៥-លោក ថាច់ សឺន ៦-លោក កៀង សួន ។ ជាប់គុក២០ឆ្នាំចំនួន៤នាក់ ១៥ឆ្នាំចំនួន៤នាក់ ១៣ឆ្នាំម្នាក់ ៥ឆ្នាំម្នាក់ និង ៣ឆ្នាំម្នាក់ ។

នៅឆ្នាំ១៩៨៥-១៩៨៧ អាជ្ញាធរអាណានិគមវៀតណាមបានចាប់ព្រះសង្ឃ និងអ្នកប្រាជ្ញបញ្ញវន្តខ្មែរកម្ពុជាក្រោមចំនួន៤២៤៨នាក់ ដាក់ពន្ធនាគារធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ រហូតដល់បាត់បង់ជីវិតរាប់រយនាក់ និងមួយចំនួនទៀតធ្លាក់ខ្លួនពិការរហូតសព្វថ្ងៃ ។ ក្នុងនោះមានព្រះតេជគុណ **គឹម សាង** សង្ឃនាយកខ្មែរកម្ពុជាក្រោមបានសុគតក្នុងឆ្នាំ១៩៨៧ ។ ព្រះតេជគុណ ថាច់ ភោគ សង្ឃនាយករង ។ ព្រះតេជគុណ **គឹម តុកចើង** ព្រះមេគុណខេត្តព្រះត្រពាំង ត្រូវគេចាក់ថ្នាំធ្វើគតនៅក្នុងពន្ធនាគារនៅឆ្នាំ១៩៨៧ ។ ព្រះតេជគុណ ថាច់ ពេជ្រ ព្រះតេជគុណ ថាច់ រាជ ព្រះតេជគុណ ថាច់ **ងស់** ។ ព្រះតេជគុណ ថាច់ ភិន ។ ព្រះតេជគុណ ថាច់ សេរី ។ ព្រះតេជគុណ ថាច់ អ៊ិក ។ ព្រះតេជគុណ សឺន យូ ។ ព្រះតេជគុណ ថាច់ ថាញ ។ ព្រះតេជគុណ ថាច់ ហាយ ។ លោកបណ្ឌិត ហាញ់ សុវណ្ណ ។ លោក ថាច់ ជុំ ថាច់ ជីវ ថាច់ ផាន ថាច់ គង់ ថាច់ កុង ។ល។ និង ។ល។

នៅក្នុងព្រឹត្តិការណ៍តស៊ូជាប្រវត្តិសាស្ត្រ ដើម្បីបុព្វហេតុពូជសាសន៍ខ្មែរកម្ពុជាក្រោម យើងមិនអាចបំភ្លេចមហាវីរបុរស ឧកញ៉ា **សឺន គុយ** ចៅហ្វាយខេត្តព្រះត្រពាំង រួមជាមួយសហការីជំនិត មានជាអាទិ៍ លោក **តាម៉ង់** លោក **ម៉ឺន ឯក** លោក **ទេសា សោម** និងលោក **មនោ រស់** បានទេ ព្រោះលោកបានដឹកនាំប្រជារាស្ត្រខ្មែរកម្ពុជាក្រោមប្រយុទ្ធបណ្តេញអាណានិគមវៀតណាមចេញពីទឹកដីកម្ពុជាក្រោមយ៉ាងខ្លាំងក្លាបំផុត ។ ប៉ុន្តែដោយការតស៊ូមិនចាញ់មិនឈ្នះ ហើយអាជ្ញាធរអាណានិគមវៀតណាមបានបង្កើនសកម្មភាពកាប់សម្លាប់ប្រជារាស្ត្រខ្មែរកាន់តែធ្ងន់ធ្ងរឡើងគ្មានត្រាប្រណី វត្តអារាមត្រូវដុតបំផ្លាញគ្រប់ទិសទី ព្រះសង្ឃខ្មែរត្រូវបង្ខំឲ្យកោសក់ទុកចិញ្ចើមស្លូត្រធម៌គោះត្រដោកដូចព្រះសង្ឃវៀតណាម ប្រជារាស្ត្រខ្មែរត្រូវបង្ខំឲ្យបោះបង់ចោលទំនៀមទម្លាប់ប្រពៃណីដ៏ល្អផូរផង់របស់ខ្លួនដោយមិនអាចតវ៉ា ស្ថិតនៅចំពោះមុខស្ថានភាពសោកនាដកម្មដ៏សែនធ្ងន់ធ្ងរបែបនេះ បានធ្វើអោយលោកឧកញ៉ា **សឺន គុយ** មេទ័ពដ៏កំពូលរូបនេះ បានសំរេចចិត្តចូលខ្លួនចរចាជាមួយអាជ្ញាធរអាណានិគមវៀតណាម ដើម្បីឲ្យអាជ្ញាធរអាណានិគមវៀតណាម បញ្ឈប់ការកាប់សម្លាប់ប្រជារាស្ត្រខ្មែរ បញ្ឈប់ការដុតបំផ្លាញវត្តអារាម ការរំលាយវប្បធម៌ អក្សរសាស្ត្រខ្មែរ ដោយលោកសុខចិត្តឲ្យអាជ្ញាធរអាណានិគមវៀតណាម កាត់ ក ទាំងរស់ ជាថ្នូរនឹងការរក្សាទុកពូជសាសន៍ ព្រះពុទ្ធសាសនា ទំនៀមទំលាប់ វប្បធម៌ អក្សរសាស្ត្រខ្មែរ នៅកម្ពុជាក្រោម ។

ក្រោយពីមហាវីរបុរសឧកញ៉ា **សឺន គុយ** បានទទួលមរណភាពនៅឆ្នាំ១៨២១ ដែលអាជ្ញាធរអាណានិគមយួនកាត់ ក ទាំងរស់នៅមុខសាលាខេត្តព្រះត្រពាំង ជាថ្នូរប្តូរនឹងភាពគង់វង្សពូជសាសន៍ សាសនា វប្បធម៌ខ្មែរនៅកម្ពុជាក្រោមនោះមក ភាពសុខសាន្តរបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបានកើតមានឡើងតែមួយរយៈខ្លីប៉ុណ្ណោះ ។ អាជ្ញាធរអាណានិគមវៀតណាម បានចាប់ផ្តើមអនុវត្តន៏យុទ្ធសាស្ត្រប្រល័យពូជសាសន៍ខ្មែរដដែល ។

រីឯព្រះមហាវីរក្សត្រខ្មែរជាទីសក្ការៈរបស់យើង ជាបន្តបន្ទាប់តែងតែបានប្រយុទ្ធតស៊ូយ៉ាងស្វិតស្វាញ ដើម្បីទាមទារទឹកដីកម្ពុជាក្រោមមកវិញជារៀងរហូត ក្នុងនោះមានព្រះបាទ**អង្គតួ**នៅឆ្នាំ១៦៤៥ ។ ព្រះបាទ **អង្គចន្ទ** នៅឆ្នាំ១៦៥៣ ។ ព្រះបាទធម្មរាជាអង្គស្ងួ នៅឆ្នាំ១៧៣៨-១៧៤៧ ។ ព្រះបាទរាមរាជាអង្គទន់ នៅឆ្នាំ១៧៧៦ ពិសេសក្នុងរជ្ជកាលព្រះបាទ**អង្គឌួង** ព្រះអង្គបានតស៊ូយ៉ាងប្អូរផ្តាច់បំផុតទាំងផ្នែកយោធា ទាំងផ្នែកការទូត ដើម្បីដណ្តើមយកទឹកដីកម្ពុជាក្រោមមកវិញ ។ ព្រះបាទ**អង្គឌួង**បានផ្ញើចុតហ្មាយពីរលើកជូនអធិរាជណាប៉ូឡេអុងទី៣ មួយច្បាប់លើកទី១ នៅខែវិច្ឆិកា ឆ្នាំ១៨៥៣ និងលើកទី២ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៨៥៦ ។

នៅឆ្នាំ១៨៦៤ ព្រះកុណាព្រះបាទ នរោត្តម បានយាងទៅកាន់ទីក្រុងព្រៃនគរ ដែលអមដំណើរដោយលោកឧត្តមនាវីទោ **Doudart de Lagrée** ដើម្បីជួបលោកអគ្គទេសាភិបាលបារាំងទាមទារខេត្តមួយចំនួនមកវិញ ។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៤៥ ព្រះកុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានចេញរាជប្រកាសមួយបញ្ជាក់អំពីអធិបតីភាពរបស់ព្រះរាជាណាចក្រកម្ពុជាលើទឹកដីកូសាំងស៊ីន និងបានស្នើសូមឲ្យមានការកំណត់ព្រំដែនឲ្យបានច្បាស់លាស់ ប៉ុន្តែអាណានិគមបារាំងមិនអើពើឡើយ ។ ព្រះរាជសារចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៤៨ ជូនលោកអគ្គស្នងការជាន់ខ្ពស់បារាំងនៅឥណ្ឌូចិន ព្រះកុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានសម្តែងនូវការប្រឆាំងដាច់ខាតចំពោះការបង្រួបបង្រួមទឹកដីទាំង៣ប្រទេស គឺប្រទេសយួន ប្រទេសចម្ប៉ា និងកម្ពុជាក្រោម (កូសាំងស៊ីន) ដែលភាសាយួនហៅថា Bac Ky, Trung Ky, Nam Ky របស់អាជ្ញាធរវៀតណាមឲ្យទៅជាប្រទេសវៀតណាមតែមួយ ព្រោះទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា ។

នៅថ្ងៃទីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៣ ព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានឡាយនៅក្នុងព្រះរាជសារមួយច្បាប់ជូនជនរួមជាតិរបស់ព្រះអង្គកាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៣ថា "ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជជាបន្តបន្ទាប់ និង នរោត្តម សីហនុ មិនដែលប្រគល់ទឹកដីមាតុភូមិកម្ពុជា សូម្បីតែមួយចំអាមជូនទៅឲ្យវៀតណាម ថៃ ឬឡាវនោះទេ ។ នៅក្នុងសម័យណាក៏ដោយ ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសឡាវ មិនដែលមានគុណអ្វីមកលើព្រះរាជាណាចក្រកម្ពុជា ហើយមហាក្សត្រខ្មែរ និង នរោត្តម សីហនុ មិនដែលក្បត់ជាតិ ប្រជារាស្ត្រមាតុភូមិកម្ពុជាម្តងណាឡើយ" ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៥ ព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានមានព្រះរាជបន្ទូលនៅក្នុងព្រះរាជសារមួយច្បាប់ទៀតមានជាអាទិ៍ថា ការកាត់ទឹកដីខ្មែរកម្ពុជាក្រោមទៅឲ្យវៀតណាម នៅឆ្នាំ១៩៤៩នោះ ជាការខុសច្បាប់ និងអយុត្តិធម៌បំផុត យ៉ាងហោចណាស់ក៏អាណានិគមបារាំងត្រូវប្រគល់ទឹកដីកម្ពុជាក្រោម៥០ភាគរយ មកឲ្យព្រះរាជាណាចក្រកម្ពុជាដែរ ។

ព្រឹត្តិការណ៍ទាំងអស់នេះ បានបញ្ជាក់យ៉ាងច្បាស់ថា ទាំងព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ ទាំងប្រជារាស្ត្រខ្មែរម្ចាស់ទឹកដី ទោះស្ថិតនៅក្នុងកាលៈទេសៈបែបណាក៏ដោយ ក៏ពុំដែលបោះបង់ចោលទឹកដីកម្ពុជាក្រោមម្តងណាឡើយ ។ កុំថាឡើយដល់ការបោះបង់ឬកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យយួន សូម្បីតែការកំណត់ព្រំដែនរវាងយួន និងខ្មែរក៏ពុំធ្លាប់មានដែរ ។

សោកនាដកម្មដ៏ខ្លោចផ្សារបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមទាំងអស់នេះ ពុំត្រូវបានសហគមន៍អន្តរជាតិដឹងឮទេ មិនខុសពីសម័យខ្មែរក្រហម៣ឆ្នាំ៨ខែ និង២០ថ្ងៃឡើយ ។ ទើបតែនៅឆ្នាំ២០០០នៃសហសវត្សរ៍ថ្មី យើងទាំង

អស់គ្នា បានប្រកាសជាឱឡារិកក្នុងពិធីអបអរសាទរសហសវត្សថ្មីនៅសាលសន្និសីទចតុមុខថ្ងៃទី០១ ខែមករា ឆ្នាំ២០០០ ថា យើងចាប់ផ្តើមបើកទំព័រប្រវត្តិសាស្ត្រថ្មីបន្តការតស៊ូពីបុព្វបុរសរបស់យើង ដើម្បីសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមជាបន្តទៀត ជាពិសេសលាតត្រដាងការពិត នៃបទឧក្រិដ្ឋទាំងឡាយរបស់អាជ្ញាធរអាណានិគមវៀតណាមបានប្រព្រឹត្តិមកលើព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ឲ្យសហគមន៍ជាតិ និងអន្តរជាតិ បានដឹងក្នុងគោលដៅសុំជួយការឧបត្ថម្ភគាំទ្រដាក់ការគាបសង្កត់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ឲ្យគោរពសិទ្ធិសេរីភាពប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ។

ដោយមានការចូលរួមយ៉ាងសកម្មពីព្រះសង្ឃ ប្រជារាស្ត្រខ្មែរនៅគ្រប់ទិសទី ក្នុងការតស៊ូដោយអហិង្សាយ៉ាងប្តូរផ្តាច់ បានធ្វើឲ្យសហគមន៍ជាតិ-អន្តរជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំង និងបានដឹងឮយ៉ាងច្បាស់អំពីទុក្ខសោកវេទនាដ៏សែនឈឺចាប់របស់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមយ៉ាងពិតប្រាកដ ។ មិនតែប៉ុណ្ណោះសហគមន៍ខ្មែរកម្ពុជាក្រោមត្រូវបានអង្គការអន្តរជាតិនានាទទួលយកចូលជាសមាជិក ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ ចាប់តាំងពីអាណានិគមវៀតណាម និងអាណានិគមបារាំងត្រួតត្រាដែនដីកម្ពុជាក្រោមរហូតមក ។ នេះជាពន្លឺនៃសេចក្តីសង្ឃឹមថ្មីមួយរបស់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមថា ថ្ងៃណាមួយនឹងទទួលបាននូវសិទ្ធិសេរីភាពពេញលេញ ដូចមនុស្សជាតិនានានៅលើសកលលោកជាក់ជាមិនខាន ។ ពីព្រោះការវិវត្តិរបស់ពិភពលោកនាពេលបច្ចុប្បន្ន នឹងឈានទៅដល់តម្រូវឲ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗគោរពសិទ្ធិពលរដ្ឋរបស់ខ្លួនឲ្យបាន ត្រឹមត្រូវស្របតាមបទដ្ឋាននានាស្តីអំពីសិទ្ធិមនុស្សជាអន្តរជាតិ ។ ការវិវត្តិនេះ បាននិងកំពុងធ្វើដំណើរស្របទិសគ្នាជាមួយការតស៊ូយ៉ាងក្តៅគគុករបស់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ក្នុងការទាមទារសិទ្ធិសេរីភាពរបស់ខ្លួន ។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមព្រះអនុញ្ញាត និងអនុញ្ញាតជំរាបជូននូវប្រវត្តិសាស្ត្រសង្ខេបនៃទឹកដីកម្ពុជាក្រោម ដូចតទៅនេះ :

២០០០ឆ្នាំប្រវត្តិសាស្ត្រនៃទឹកដីខ្មែរ ប្រជារាស្ត្រ និងព្រះមហាក្សត្រខ្មែរបានធ្វើការតស៊ូយ៉ាងស្វិតស្វាញបង្កើតបានជាព្រះរាជាណាចក្រមួយដ៏ធំល្វឹងល្វើយនៅតំបន់អាស៊ីអគ្នេយ៍ ។ ព្រះរាជាណាចក្រនេះ ត្រូវបានបង្កើតឡើងដោយរដ្ឋពីររួមបញ្ចូលគ្នាគឺ ដែនដីទំនាបលិចទឹកហៅថា **ហ្វូណន** (កម្ពុជាក្រោម) ស្ថិតនៅខាងកើតឆៀងខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នជាចំណែកមួយនៃទឹកដីសាធារណរដ្ឋសង្គមនិយមវៀតណាមប៉ែកខាងត្បូង និងដែនដីផ្នែកខាងលើអាងមេគង្គហៅថា **ចេនឡា** (កម្ពុជា) ។ នៅពាក់កណ្តាលសតវត្សរ៍ទី៦ ព្រះអង្គម្ចាស់ **ភវវរ្ម័ន**ក្នុងសន្តិវង្ស **ហ្វូណន** ជាព្រះរាជនត្តាព្រះបាទ **រុទ្រវរ្ម័ន** បានរៀបអភិសេកជាមួយព្រះអង្គម្ចាស់ក្សត្រីព្រះនាម **កម្ពុជរាជលក្ស្មី** ព្រះញាតិខាងព្រះមាតាព្រះបាទស្រេស្ឋវរ្ម័ននៅនគរចេនឡានៃសន្តតិវង្ស **ទ្រុឌវរ្ម័ន** ។ ក្រោយពីបានរៀបព្រះអភិសេករួចហើយ ព្រះបាទ**ភវវរ្ម័ន**បានឡើងសោយរាជ្យនៅនគរ**ចេនឡា**ក្នុងឆ្នាំ៥៥០ ។ បន្ទាប់ពីបានឡើងគ្រងរាជ្យសម្បត្តិភ្លាម ព្រះអង្គបានខិតខំបង្រួបបង្រួមនគរទាំងពីរគឺ **ហ្វូណន** និង **ចេនឡា** ឲ្យទៅជានគរតែមួយគឺព្រះរាជាណាចក្រ "**កម្ពុជា**" ។ ព្រោះប្រជារាស្ត្រក្នុងរដ្ឋទាំងពីរនេះ បាននិយាយភាសាខ្មែរ និងមានវប្បធម៌ទំនៀមទម្លាប់ដូចគ្នា ដូចនេះក្រុមអ្នកប្រវត្តិវិទូបានអះអាងដោយឯកភាពគ្នាថា ព្រះបាទ **ភវវរ្ម័ន** ជាស្ថាបនិកនៃព្រះរាជាណាចក្រកម្ពុជាដ៏ពិតប្រាកដមិនអាចប្រកែកបាន ។ តាមឯកសារប្រវត្តិសាស្ត្របានសរសេរថា ទីក្រុងព្រៃនគរ ដែលយួនហៅថា សៃហ្គន បច្ចុប្បន្នទីក្រុងហូជីមិញ ជាអតីត រាជធានីរបស់ខ្មែរដែលព្រះមហាក្សត្រខ្មែរទាំងឡាយបានគង់ប្រថាប់តាំងពីឆ្នាំ២៨៥មុនគ្រិស្តសករាជ ។ ការលើកឡើងសង្ខេបខ្លីនៃប្រវត្តិសាស្ត្រនេះ ដើម្បីបញ្ជាក់ថា ទឹកដីកម្ពុជាក្រោមជាទឹកដីខ្មែរពិតប្រាកដ ប្រជារាស្ត្រខ្មែរជាម្ចាស់ទឹកដីពិតប្រាកដ ។ ក្រោយការបង្កើតបានជា

ព្រះរាជាណាចក្រកម្ពុជា ការប្រេះឆាផ្ទៃក្នុង និងភាពរីកចំរើន បានកើតមានជាបន្តបន្ទាប់ ទីបំផុត ព្រះរាជាណាចក្រកម្ពុជាបានរីកចំរើនដល់កំពូល និងបានក្លាយជាមហាចក្រមួយដ៏ធំនៅតំបន់អាស៊ីយើងនេះ ។ ប៉ុន្តែជាអកុសល នៅឆ្នាំ១៦២៣ វត្តមានអន្តោប្រវេសន៍យួនខុសច្បាប់ បានហូរចូលទឹកដីនៃព្រះរាជាណាចក្រកម្ពុជាយ៉ាងគំហុក តាមរយៈព្រះនាង ង្វៀង ង៉ុកវ៉ឹង បុត្រីស្តេចយួនឈ្មោះ ង្វៀង សាយវឿង ដែលត្រូវជាព្រះរាជអគ្គមហេសីព្រះបាទជ័យជេដ្ឋាទី២ ។ ក្រោយពីព្រះបាទជ័យជេដ្ឋាទី២សោយទីវង្គត់(១៦១៨-១៦២៨) ព្រះមហាក្សត្រខ្មែរជាបន្តបន្ទាប់ បានទាមទារទឹកដីដែលព្រះបាទជ័យជេដ្ឋាទី២បានឲ្យយួន ខ្ចីធ្វើជាគ្រឹះស្ថានជំនួញនៅកោះក្របីព្រៃនគរមកវិញ ប៉ុន្តែត្រូវបានយួនបដិសេធជានិច្ច ។ មូលហេតុនេះហើយ ដែលធ្វើឲ្យទឹកដីខ្មែរប៉ែកខាងក្រោម (កម្ពុជាក្រោម) របេះបន្តិចម្តងៗរហូតដល់ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ អាណានិគមបារាំងបានកាត់ឲ្យអាណានិគមវៀតណាម ត្រួតត្រាបន្តរហូតបច្ចុប្បន្ន ដោយមិនបានសួរមតិប្រជារាស្ត្រខ្មែរ ឬ ព្រះមហាក្សត្រខ្មែរដែលជាម្ចាស់ទឹកដីឡើយ ។

ការលើកឡើងសង្ខេបខ្លីនៃប្រវត្តិសាស្ត្រនេះ ដើម្បីបញ្ជាក់ថា ទឹកដីកម្ពុជាក្រោមជាទឹកដីខ្មែរពិតប្រាកដ ប្រជារាស្ត្រខ្មែរជាម្ចាស់ទឹកដីពិតប្រាកដ។

ទោះបីអាណានិគមបារាំង បានកាត់ទឹកដីកម្ពុជាក្រោមឲ្យអាជ្ញាធរវៀតណាមក៏ដោយ ទោះបីអាជ្ញាធរអាណានិគមវៀតណាមបានប្រើគ្រប់ល្បិចកលធ្វើបាបកាប់សម្លាប់ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម ដើម្បីបង្ខំឲ្យគោរពតាមនយោបាយវៀតណាមូបនីយកម្មយ៉ាងណាក៏ដោយ ក៏ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម មិនបានបោះបង់សញ្ជាតិខ្មែរ ទំនៀមទំលាប់ វប្បធម៌ ព្រះពុទ្ធសាសនារបស់ខ្លួន ឬចូលជាតិសាសន៍យួនម្តងណាទេ គឺនៅតែរក្សាអត្តសញ្ញាណជាតិជាខ្មែរដដែល ហើយបានចាត់ទុកទឹកដីកម្ពុជាក្រោមជាកម្មសិទ្ធិស្របច្បាប់របស់ប្រជារាស្ត្រខ្មែរ ។ ទង្វើរបស់អាណានិគមបារាំង ជាទង្វើខុសច្បាប់ និងអយុត្តិធម៌បំផុតចំពោះប្រជារាស្ត្រខ្មែរម្ចាស់ស្រុក ដែលខ្មែរគ្រប់រូបមិនអាចទទួលយកបានឡើយ ។ ការត្រួតត្រារបស់អាជ្ញាធរអាណានិគមវៀតណាមសព្វថ្ងៃ គ្រាន់តែជាការបន្តផនពីអាណានិគមបារាំងប៉ុណ្ណោះ ។

*បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
*គណៈអធិបតីជាទីគោរព*
*បងប្អូនរួមជាតិជាទីស្នេហា*

តាមរយៈវេទិកាថ្ងៃនេះ ខ្ញុំសូមអំពាវនាវដល់ព្រះសង្ឃ និងបងប្អូនរួមជាតិ ព្រះមេត្តា និងមេត្តាសាមគ្គីគ្នាជាធ្លុងមួយ ចូលរួមនូវគ្រប់ពិធីដែលរៀបចំដោយអង្គការសមាគមខ្មែរកម្ពុជាក្រោម ក្នុងគោលដៅតស៊ូដោយអហិង្សា និងស្របច្បាប់ ស្របតាមបទដ្ឋាននានាស្តីអំពីសិទ្ធិមនុស្ស សិទ្ធិជនជាតិដើមរបស់អង្គការសហប្រជាជាតិ ដើម្បីទាមទារសិទ្ធិសេរីភាពជូនប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ។ មានតែការចូលរួមឲ្យបានគ្រប់គ្នា មានតែការសាមគ្គីជាធ្លុងមួយនេះទេ ដែលជាកម្លាំងចលករដ៏មានប្រសិទ្ធភាព ជំរុញការតស៊ូរបស់យើងទទួលជោគជ័យដ៏ឆាប់បំផុត ។

ជាមួយគ្នានេះដែរ សហគមន៍ខ្មែរកម្ពុជាក្រោមទូទាំងពិភពលោក សូមអំពាវនាវដល់រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា មេត្តាបំពេញតួនាទីរបស់ខ្លួនឲ្យបានពេញលេញ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការការពារប្រជារាស្ត្រខ្មែរកំណើតកម្ពុជាក្រោម ទាំងនៅព្រះរាជាណាចក្រកម្ពុជា ទាំងនៅកម្ពុជាក្រោម និងសូមអំពាវនាវអង្គការជាតិ អន្តរជាតិ និងបណ្តាប្រទេសស្រឡាញ់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សទាំងអស់ ដាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមឲ្យខ្លាំងក្លា ដើម្បីបង្ខំឲ្យរដ្ឋាភិបាលកុម្មុយនិស្តមួយនេះ/K

បញ្ឈប់ជាបន្ទាន់នូវរាល់ការរឹបអូសយកដីធ្លីពីប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម បញ្ឈប់នូវការធ្វើទុក្ខបុកម្នេញ សម្លុតគំរាម ការបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការទទួលព័ត៌មាន ការសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ ការគោរពទំនៀមទម្លាប់ និងជំនឿសាសនាជាដើម ជាពិសេសដោះលែងប្រជារាស្ត្រខ្មែរដែលអាជ្ញាធរអាណានិគមវៀតណាមបានចាប់ខ្លួនដាក់ពន្ធនាគារដោយសារតែតស៊ូដើម្បីការពារដីស្រែចំការរបស់ពួកគេដោយឥតលក្ខណ្ឌ ។

ដូច្នេះ ដើម្បីសំដែងនូវការគោរព និងដឹងគុណចំពោះគុណូបការៈដ៏ថ្លៃថ្លារបស់ព្រះមហាវីរក្សត្រ ព្រះវីរសមណៈ និងវីរបុរស-វីរនារី យុទ្ធជន-យុទ្ធនារីខ្មែរស្នេហាជាតិដ៏ជាទីគោរពសក្ការៈ នៃយើងទាំងអស់គ្នាថ្ងៃនេះ អង្គការសមាគមខ្មែរកម្ពុជាក្រោម បាននៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ ឧទ្ទិសកុសលប្រគេនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ថ្វាយព្រះវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រ និងជូនវិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរទាំងអស់ដែលបានតស៊ូប្ដូរជាជីវិតក្នុងបុព្វហេតុពូជសាសន៍ សាសនា និងទឹកដីខ្មែរទាំងមូល ពិសេសទឹកដីខ្មែរកម្ពុជាក្រោម ។ ពិធីនេះក៏ជាការប្រារព្ធទិវាកាន់ទុក្ខជាតិខ្មែរខួបគំរប់៦១ឆ្នាំ នៃថ្ងៃអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោម ឲ្យអាជ្ញាធរអាណានិគមវៀតណាមផងដែរ ។ សូមឧត្តមគតិស្នេហាជាតិដ៏ថ្លៃថ្លារបស់បុព្វបុរសខ្មែរគ្រប់ជំនាន់ស្ថិតក្នុងស្មារតីកូនខ្មែរគ្រប់រូប ដើម្បីកុំឲ្យមានប្រវត្តិសាស្ត្រចាស់វិលមក ជាថ្មីទៀត ។

*គ្មានអ្វីឈឺចាប់ជាងបាត់បង់ទឹកដី និងក្លាយខ្លួនជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួនឡើយ។*

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជនទាំងអស់ ទាំងបងប្អូនរួមឈាមនៅឯនាយសមុទ្រទាំងនៅព្រះរាជាណាចក្រកម្ពុជា ដែលបានជួយឧបត្ថម្ភក្នុងការរៀបចំពិធីបុណ្យ ដែលប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានរបស់ព្រះតេជគុណគ្រប់ព្រះអង្គ ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ និងបងប្អូនជនរួមឈាមទាំងអស់ដែលបាននិមន្ត និងអញ្ជើញចូលរួមក្នុងពិធីបុណ្យយ៉ាងអធិកអធម ។

ដោយឥទ្ធិមនុញ្ញផលដែលកើតមានអំពីបុណ្យកតញ្ញូកតវេទិតាធម៌នេះ យើងខ្ញុំសូមឧទ្ទិសកុសលទាំងនេះប្រគេន ថ្វាយ និងជូនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារី បានសោយសុខក្នុងសុគតិភព និងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រៃ និងវត្ថុសក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ជួយបីបាច់ថែរក្សា ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាវីរក្សត្រ និងសម្តេចព្រះរាជអគ្គមហេសី ព្រមទាំងព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រខ្មែរជាកូន ចៅ ចៅទួតរបស់ព្រះអង្គជាយូរអង្វែងតរៀងទៅ និងសូមថ្វាយព្រះពរ សម្តេចស៊ីសុវត្ថិ ពង្សនារី មុនីពង្ស ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាព្រះអធិបតីក្នុងពិធីបុណ្យ និងគោរពប្រគេនពរ និងជូនពរព្រះសង្ឃ ព្រមទាំងប្រជារាស្ត្រខ្មែរទាំងអស់ សូមទទួលបាននូវសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ដូចមនុស្សជាតិនានានៅលើសកលលោក ព្រមទាំងបានប្រកបដោយពុទ្ធពរទាំងឡាយ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

***សូមអរព្រះគុណ និងអរគុណ***